# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អន.ក្របក ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្រលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### សម្រេច

**មាត្រា ១:** ត្រូវបានអនុញ្ញាតអោយ បង្កើតគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយ ដែលមាន ឈ្មោះថា វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា ហៅកាត់ " វពក " និងជាភាសាអង់គ្លេស BUSINESS INSTITUTE OF

CAMBODIA ហៅកាត់ " BIC " ។ វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជានេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ភូមិលេខ ៣ ឃុំកំពង់លាវ ខេត្តព្រៃវែង ។

**មាត្រា ២:** វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា ធ្វើការបណ្តុះបណ្តាល

- ថ្នាក់វិញ្ញាបនបត្រ បណ្តុះបណ្តាលរយៈពេលខ្លី ក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- ថ្នាក់សញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ រឺ ២ឆ្នាំ រឺ ៣ឆ្នាំ ( ៩+ ១+១+១ )
- ថ្នាក់សញ្ញាប័ត្រជាន់ខ្ពស់បច្ចេកទេស រឺ ឯកទេស សិក្សារយពេលយ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៨០ក្រេឌីត
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយពេលយ៉ាងតិច ៤ ឆ្នាំ ត្រូវជា ១២០ ឬ ១៣០ក្រេឌីត ។

**មាត្រា ៣:** វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជាមាន រចនាសម្ព័ន្ធដូចខាងក្រោម

១- ដេប៉ាតឺម៉ង់ ហិរញ្ញវត្ថុ និងធនាគារ

២- ដេប៉ាតឺម៉ង់ គណនេយ្យ

៣- ដេប៉ាតឺម៉ង់ ទីផ្សារ

៤- ដេប៉ាតឺម៉ង់ សណ្ឋាគារ និងទេសចរណ៍

៥- ដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម

៦- ដេប៉ាតឺម៉ង់ ព័ត៌មានវិទ្យា

៧- ដេប៉ាតឺម៉ង់ ភាសាបរទេស

៨- មានសាខាពីរ សាខាខេត្តតាកែវ និងស្វាយរៀង

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើក ដេប៉ាតឺម៉ង់ សាខារឺឯកទេសដទៃទៀតដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤:** វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និងសំរេច លើគោលនយោបាយ និងផែនការអភិវឌ្ឍន៏ របស់វិទ្យាស្ថាន និងមានក្រុមប្រឹក្សាបច្ចេកទេសវិទ្យាសាស្ត្រមួយ ដែលសមាជិកក្រុមប្រឹក្សានេះ មានសញ្ញាប័ត្រចាប់ពីកំរិតឧត្តមសិក្សាឡើងទៅ សំរាប់ពិនិត្យ និងផ្តល់យោបល់លើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥:** ល័ក្ខខ័ណ្ឌទទួលសិស្សអោយចូលរៀន

- ថ្នាក់សញ្ញាប័ត្របច្ចេកទេស និងវិជ្ជាជីវៈ បេក្ខជនបានរៀនចប់ថ្នាក់ទី ៩ នៃមធ្យមសិក្សាបឋមភូមិ ។
- ថ្នាក់សញ្ញាប័ត្រជាន់ខ្ពស់បច្ចេកទេស រឺ ឯកទេស បេក្ខជនទាំង២ភេទបានប្រឡងជាប់ រឺ ធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បរិញ្ញាប័ត្រ បេក្ខជនទាំង២ភេទ ត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំណត់អំពីការជ្រើសរើសសិស្ស និស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

**មាត្រា ៦:** នាយក វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា មានភារកិច្ច :

- ជ្រើសរើស សិស្ស និស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។

- គ្រប់គ្រងអោយបានល្អ នូវការងារសិស្ស និស្សិត ការងារសិក្សា ការងារបង្រៀន ការស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និងអនុវត្តតាមសារាចរ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ( នាយកដ្ឋានជំនាញ ) ឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៧ៈ** សិស្ស និស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថាននេះ នឹងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានសញ្ញាប័ត្រតាមកំរិតនិងតាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះត្រូវបានផ្តល់ជូនឱ្យដោយវិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា ហើយទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៨ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងវិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជាត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៩/១០ ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ក្រសួងអប់រំយុវជន និងកីឡា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា
- -គ្រប់ខេត្ត ក្រុង
- -ដូចមាត្រា ៨
- -ឯកសារ-កាលប្បវត្តិ